ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:.១៣៧..សជណ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មការអន្តរក្រសួង
ដើម្បីរៀបចំ និងចូលរួមពិព័រណ៌ពិភពលោក និងពិព័រណ៌ពាណិជ្ជកម្មអន្តរជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការ កែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣១ អនក្របក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រេច

ប្រការ១ .-

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីរៀបចំ និងចូលរួមពិព័រណ៌ពិភពលោក និង ពិព័រណ៌ពាណិជ្ជកម្មអន្តរជាតិ នៅបណ្តាប្រទេសលើពិភពលោក ដែលមានសមាសភាពដូចខាងក្រោម:

១-ឯកឧត្តម **ស៊ុន ចាន់ថុល**	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម	ប្រធាន
២-ឯកឧត្តម **ឈួន ជាវ៉ា**	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	អនុប្រធាន

៣-ឯកឧត្តម **ប៉ាក់ សុខុម**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធាន
៤-ឯកឧត្តម **ឆាន់ ភឌ្ឍនៈ**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៥-លោកជំទាវ **ឆឺង ស៊ីមន**	អនុរដ្ឋលេខាធិការទទួលបន្ទុកការងារសិល្បៈ និង ទស្សនីយភាព នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	សមាជិកា
៦-ឯកឧត្តម **កែ គី**	អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម	សមាជិក
៧-ឯកឧត្តម **កៅ ឆារ៉ូ**	អនុរដ្ឋលេខាធិការក្រសួងព័ត៌និងថាមពល	សមាជិក
៨-ឯកឧត្តម **ចាន់ សុភុឌ្ឍ**	អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៩-ឯកឧត្តម **សឺង រេត**	ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
១០-ឯកឧត្តម **ជា តុង្គី**	អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
១១-ឯកឧត្តម **កែ សុភណ្ណា**	អគ្គនាយកជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម	សមាជិកអចិន្ត្រៃយ៍
១២-ឯកឧត្តម **ហាប់ ឆួច**	អគ្គនាយកបច្ចេកទេសវប្បធម៌ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	សមាជិក
១៣-លោក **ខៀប សេរីវិសិទ្ធ**	អគ្គនាយករងនៃអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងព័ត៌និងថាមពល	សមាជិក
១៤-លោក **ហេង សោភ័ណ**	អគ្គនាយករងនៃអគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យមនិងសិប្បកម្ម នៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម	សមាជិក
១៥-លោក **សុខ ជារិទ្ធិ**	ប្រធាននាយកដ្ឋានកិច្ចការពិព័រណ៌នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម	សមាជិក
១៦-លោក **សារុន រ៉ាឌី**	ប្រធាននាយកដ្ឋានផ្ទៃក្នុងនៃទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
១៧-លោក **ម៉ាក់ សឿន**	ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
១៨-លោក **អ៊ូ សុផល**	ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ នៃក្រសួងពាណិជ្ជកម្ម	សមាជិក
១៩-លោក **ជា ភឿត**	អនុប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈនិងជំរុញវិនិយោគឯកជននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
២០-លោក **ស្រី ឆុង**	អនុប្រធាននាយកដ្ឋានហិរញ្ញកិច្ចនៃអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក

ប្រការ២ .-

គណៈកម្មការអន្តរក្រសួងនេះ មានការកិច្ចដូចតទៅ៖

- ចូលរួមពិព័រណ៌ពិភពលោក ឆ្នាំ២០១៥ នៅទីក្រុងមីឡង់ នៃប្រទេសអ៊ីតាលី ក៏ដូចជាពិព័រណ៌ពាណិជ្ជកម្មអន្តរជាតិ និងពិព័រណ៌ពិភពលោកបន្តបន្ទាប់ ដើម្បីបម្រើការតាំងពិព័រណ៌ពិភពលោក នៃបណ្តាប្រទេសផ្សេងៗ លើពិភពលោក
- ធ្វើទំនាក់ទំនងជាមួយភាគីម្ចាស់ផ្ទះ ដើម្បីចូលរួមពិព័រណ៌អន្តរជាតិ និងពិព័រណ៌ពិភពលោក
- ធ្វើទំនាក់ទំនងជាមួយបណ្តាក្រសួង-ស្ថាប័ន អង្គការជាតិ-អន្តរជាតិ និងក្រុមហ៊ុននានាដែលពាក់ព័ន្ធ ដើម្បីត្រៀមលក្ខណៈក្នុងការចូលរួមពិព័រណ៌ពិភពលោក
- ទទួលខុសត្រូវ និងចាត់ចែងការងាររៀបចំសាងសង់ពន្លាជាតិ និងសម្របសម្រួលការទទួលខុសត្រូវចំពោះស្តង់ផ្នែកឯកជន
- ជំរុញការតាំងពិព័រណ៌របស់ព្រះរាជាណាចក្រកម្ពុជា ឱ្យបានទទួលជោគជ័យយ៉ាងត្រចះត្រចង់ នៅទីក្រុងមីឡង់ នៃប្រទេសអ៊ីតាលី ខាងមុខនេះ ក៏ដូចជាពិព័រណ៌ពិភពលោក នាឆ្នាំបន្តបន្ទាប់នៅបណ្តាប្រទេសលើពិភពលោក
- ចូលរួមសន្និសីទ និងសកម្មភាពទាំងឡាយដែលរៀបចំដោយការិយាល័យពិព័រណ៌អន្តរជាតិ
- លើកយោបល់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចក្នុងករណីចាំបាច់ និងធ្វើរបាយការណ៍បូកសរុបលទ្ធផលជូនទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួង-ស្ថាប័នពាក់ព័ន្ធ នៅពេលពិព័រណ៌ពិភពលោកមួយលើកៗ ត្រូវបានបញ្ចប់។

ប្រការ៣ .-

អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ជាលេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំ និងចូលរួមពិព័រណ៌ពិភពលោក និងពិព័រណ៌ពាណិជ្ជកម្មអន្តរជាតិ។

ប្រការ៤ .-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យ និងផ្តល់ថវិកា សម្រាប់ចំណាយជូនដល់គណៈប្រតិភូដែលត្រូវអញ្ជើញទៅចូលរួមការតាំងពិព័រណ៌ពិភពលោក និងពិព័រណ៌ពាណិជ្ជកម្មអន្តរជាតិ។

ប្រការ៥ .-

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួនសម្រាប់ជំនួយការងារ។

ប្រការ៦ .-

គណៈកម្មការអន្តរក្រសួងនេះ ត្រូវស្ថិតនៅជានិរន្តរ៍ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម។

ប្រការ៧ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ប្រធានស្ថាប័ន និងសាមីខ្លួនដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ